សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ:៧៨៤/២៦.៨.២០១១
សាលដីកា
លេខ:៩០ ក្រ.III.ស/១៤.១១.២០១៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**************

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៧៨៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ដែលមានៈ

ជនជាប់ចោទឈ្មោះ [redacted] ឈាង ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរៈគ្រូបង្រៀន កើតនៅភូមិតាកោ ឃុំស្វាយយា ស្រុកស្វាយរៀង ខេត្តស្វាយរៀង បច្ចុប្បន្នរស់នៅ [redacted] ស្រុកស្វាយជ្រំ ខេត្ត ស្វាយរៀង ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ទោសពីមុនគ្មាន។

<u>ត្រូវចោទពីបទៈ</u> ជេរប្រមាថ ប្រព្រឹត្តនៅ ភូមិគោល ឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាន់ ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិគោល ឃុំស្វាយអង្គ ស្រុកស្វាយរៀង ខេត្តស្វាយរៀង។

**<u>ដំណើររឿងមានដូចតទៅៈ</u>**

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ វេលាម៉ោង ១រសៀល នៅភូមិគោល ឃុំស្វាយអង្គ ស្រុកស្វាយរៀង ខេត្តស្វាយរៀង មានអំពើល្មើសច្បាប់ព្រហ្មទណ្ឌមួយបានកើតឡើង ដែលបង្កដោយឈ្មោះ



Scanned with CamScanner

[redacted] ឈាង ភេទប្រុស ជាគ្រូបង្រៀន, មានជម្លោះបរិហាកេរ្តិ៍ និងជេរប្រមាថ ដោយប្រើពាក្យធ្ងន់ៗ ទំលាក់កំហុសទៅលើជនរងគ្រោះឈ្មោះ [redacted] វ៉ាន់ ដូចជាពាក្យថា អញកាប់ក៏បានដែរ ស្រេចតែអញ ហ្អែងខ្លាំងទៅប្តឹង អាស៊ានទៅ អាស៊ានស៊ីលុយ និងថា មីក្រហេមរហាម គ្មានដីស្រែមួយកែង ព្រមទាំងពាក្យប្រមាថមួយចំនួនទៀត ក្នុងពេលដែលឈ្មោះនេះមានជម្លោះ រឿងកាប់ទម្លាយភ្លឺស្រែ។ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៣ ឈ្មោះ [redacted] វ៉ាន់ ប្តឹងរឿងហេតុនេះទៅសមត្ថកិច្ចនគរ បាលយុត្តិធម៌ ចាត់ការតាមច្បាប់តែម្តង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៣ «ក» ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូង ខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១. ផ្តន្ទាទោសលើឈ្មោះ [redacted] ឈាង ភេទប្រុស អាយុ៤២ឆ្នាំ ឲ្យដាក់ប្រាក់ពិន័យចំនួន ៥០០.០០០រៀល (ហាសិបម៉ឺនរៀល) ដាក់ចូលថវិការដ្ឋ ពីបទ ជេរប្រមាថ ប្រព្រឹត្តនៅ ភូមិគោល ឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យ ផ្តន្ទាទោសតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ។

២. បង្គាប់ឲ្យឈ្មោ[redacted] ឈាង សងសំណងជម្ងឺចិត្ត ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះនារី [redacted] វ៉ាន់ ជាប្រាក់ចំនួន ៣០០.០០០(បីសែន)រៀល។ ការទាមទារលើសពីនេះត្រូវលើកចោល។

៣. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ លេខ ៣១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ របស់ឈ្មោះ[redacted] ឈាង ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៣ «ក» ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូង ខេត្តស្វាយរៀង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា សង្ខេបអង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ[redacted]ឈាង ឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មិនសុខចិត្ត ព្រោះខ្លួនមិនបានប្រមាថមើល ងាយលើឈ្មោះ [redacted] វ៉ាន់ ទេ សូមលោកប្រធានជួយរកយុត្តិធម៌ឲ្យខ្លួនផង, ខ្លួនមានសាក្សីបញ្ជាក់ ខ្លួនពិតជា មិនបាន និយាយដូចការចោទប្រកាន់ទេ ហើយខ្លួនក៏អត់បានក្នួរលើវាលភ្លឺស្រែគេដែរ,

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ឈាង បានឆ្លើយនៅនគរបាល និងនៅគ្រប់នីតិវិធី សាលាដំបូងខេត្តស្វាយរៀង។

ជនជាប់ចោទឈ្មោះ [redacted] ឈាង ឆ្លើយបន្ថែមថា ខ្លួនអត់បានប្រព្រឹត្តទេ, សំណូមពរ សុំសាលា ឧទ្ធរណ៍ រកយុត្តិធម៌ឲ្យខ្លួនផង និងសុំទាមទារជម្ងឺចិត្តខាតបង់ពេលវេលា។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាន់ ឆ្លើយថា ឈ្មោះ[redacted] ឈាង បាននិយាយ ដូចមានក្នុង ពាក្យបណ្តឹង ដែលខ្លួនបានដាក់មែន, ឈ្មោះ[redacted] សាន ត្រូវជាពូក្មេកខ្លួន, ឈ្មោះ[redacted] ឈាង មិនត្រឹម



Scanned with CamScanner

និយាយខ្ចីដងខ្លួនទេ និយាយដល់ពូក្មេកខ្លួទៀត, ខ្លួនក៏បានប្តឹងទៅភូមិឃុំ តែភូមិឃុំដោះស្រាយមិនចេញ ទើបខ្លួនប្តឹងមកតុលាការតែ ម្តង, សំណូមពរ សុំដូចសាលាដំបូង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្នុងសវនាការសាលាឧទ្ធរណ៍ ជនជាប់ចោទបានប្រកែក និងបដិសេធសូម្បីចម្លើយរបស់គាត់បានឆ្លើយនៅសាលាដំបូង, ប៉ុន្តែ មានសាក្សីបញ្ជាក់គ្រប់គ្រាន់, តំណាងមហាអយ្យការសុំឲ្យក្រុមប្រឹក្សាពិចារណា និងសម្រេច ទៅតាមច្បាប់។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍លេខ ៣១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ឈាង ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. ជនជាប់ចោទឆ្លើយនៅសាលាដំបូង ក៏ដូចជានៅសាលាឧទ្ធរណ៍ដែរថា ខ្លួនពុំបានជេរប្រមាថទៅលើជនរងគ្រោះឈ្មោះ [redacted] វ៉ាន់ ទេ ហើយខ្លួនក៏ពុំបានកួរវាលភ្លឺស្រែគេដែរ តែខ្លួនបានដាំដើមរំចេកលើភ្លឺស្រែផ្នែកខាងស្រែខ្លួន, ប៉ុន្តែ ខ្លួនពិតជាមានទំនាស់នឹងដើមបណ្តឹងមែន។

៣. ផ្ទុយពីចម្លើយជនជាប់ចោទនេះ សាក្សីដែលបានឃើញហេតុការណ៍ផ្ទាល់ នៅថ្ងៃកើតហេតុឈ្មោះ [redacted] មៀច ថា ឈ្មោះ [redacted] ឈាង ពិតជាបានជេរប្រមាថដោយពាក្យធ្ងន់ៗទៅលើជនរងគ្រោះថា អញកាប់ស្រេចតែអញ, អញកាប់ម៉េងគ្រវាត់ចោលក៏បានដែរ...... ជាដើម។

៤. ជនជាប់ចោទឆ្លើយបដិសេធ តែទទួលស្គាល់ថា ខ្លួនពិតជាមានទំនាស់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី មែន, ជាងនេះ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយសាក្សីឃើញហេតុការណ៍ នៅថ្ងៃកើតហេតុ ជាភស្តុតាង ធ្ងន់ល្មមទៅលើជនជាប់ចោទ។

៥. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ ជេរប្រមាថ ប្រព្រឹត្តនៅ ភូមិគោល ឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៣ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ។

៦. សាលក្រមព្រហ្មទណ្ឌលេខ ២៣ «ក» ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តស្វាយរៀង សម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។



Scanned with CamScanner

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ឈាង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៣ «ក» ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ របស់សាលា ដំបូងខេត្តស្វាយរៀង ទុកជាបានការ ពេញទាំងមូល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី, បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបាន សម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខ [redacted] |

---

| | |
|---|---|
| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
| **ប្រធានសាលាឧទ្ធរណ៍** | ភ្នំពេញ, ថ្ងៃទី ០៤ ខែ ...០៦. ឆ្នាំ ២០១៤ |
| | **ក្រឡាបញ្ជី** |



Scanned with CamScanner